ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ពេលព្រះជាម្ចាស់បាន បង្កើតរបស់គ្រប់យ៉ាង




និពន្ធដោយ៖ Edward Hughes
ផ្ទើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson
បកប្រែដោយ៖ www.christian-translation.com
កែសម្រួលដោយ៖ Bob Davies; Tammy S.



រឿងទី ១ នៃ ៦០

**www.M1914.org**

***Bible for Children,*** *PO Box 3, Winnipeg, MB R3C 2G1 Canada*



អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។


ភាសាខ្មែរ Khmer

តើនរណាបង្កើតយើងឡើង? សៀវភៅព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះប្រាប់ពីរបៀបដែលមនុស្សជាតិបានចាប់កំណើតឡើង។ កាលពីយូរលង់ណាស់មកហើយ ព្រះទ្រង់បានបង្កើតមនុស្សដំបូងបង្អស់ម្នាក់ ហើយដាក់ឈ្មោះគាត់ថា អាដាម។



1

ព្រះទ្រង់បានបង្កើតអាដាមចេញពីធូលីដី។ ទ្រង់បានប្រទានជីវិតដល់អាដាម ហើយគេក៏អាចរស់រានមានជីវិតឡើង។ គាត់បានរស់នៅក្នុងសួនដ៏ស្រស់ស្អាតមួយឈ្មោះថាអ៊ីដែន។



2

មុនពេលព្រះទ្រង់បង្កើតអាដាម, ទ្រង់បានបង្កើតពិភព លោកដ៏ស្រស់ស្អាតដែលពោរពេញទៅដោយរបស់អស្ចារ្យ។ម្តង បន្តិចៗ ព្រះទ្រង់បានបង្កើតតំបន់ភ្នំ និងទីវាលធំល្វឹងល្វើយ, ផ្កាដ៏ក្រអូប និងដើមឈើខ្ពស់ៗ, បក្សាបក្សីដែលមានរោម ស្រស់ស្អាត និងហ្វូងឃ្មុំលាន់ទ្រហឹង, ត្រីបាឡែនធំៗ និងខ្យង ដែលពោរពេញដោយភាពរអិល។ តាមពិតទៅ,




3

ដំបូងឡើយ មុនពេលព្រះបានបង្កើត គ្រប់យ៉ាង លើលោកនេះមិនមានអ្វី ឡើយ ក្រៅពីទ្រង់។ គ្មានមនុស្សម្នា ឬទីកន្លែង ឬរបស់អ្វីឡើយ។ គ្មានអ្វីសោះឡើយ។ គ្មានពន្លឺ ហើយក៏គ្មានភាព ងងឹតដែរ។ គ្មានលើ ហើយក៏គ្មានក្រោម។ គ្មានម្សិលមិញ គ្មានថ្ងៃស្អែក។ មានតែព្រះជាម្ចាស់តែ ប៉ុណ្ណោះដែលគ្មានការចាប់ផ្តើម។ ក្រោយមក ព្រះទ្រង់បានធ្វើ សកម្មភាព! ដំបូង ទ្រង់បាន បង្កើតឋានសួគ៌ និងផែនដី។



4

ហើយផែនដីគ្មានទ្រង់ទ្រាយ ហើយ ទទេរស្អាត។ ហើយភាព ងងឹតគ្របដណ្តប់លើ ជម្រៅទឹក។ ក្រោយមក ព្រះមានព្រះ បន្ទូលថា "ចូរមាន ពន្លឺឡើង"។



5

ហើយពន្លឺក៏កើតមានឡើងតាមបន្ទូលរបស់ទ្រង់។ ព្រះទ្រង់ ហៅពន្លឺថាថ្ងៃ ហើយភាពងងឹតថាជាយប់។ ហើយក៏មាន ពេលល្ងាច និងពេលព្រឹកជាថ្ងៃទីមួយ។



6

នៅថ្ងៃទីពីរ ព្រះទ្រង់បាននាំយកទឹកមហាសមុទ្រ, ទឹកស មុទ្រ និងបឹងបួរដាក់តាមលំដាប់នៅក្រោមផ្ទៃមេឃ។ នៅ ថ្ងៃទីបី, ព្រះបានមានព្រះបន្ទូលថា "ចូរមានដីស្ងួតលេច ឡើង" ហើយវាក៏កើតមានឡើងតាមបន្ទូលរបស់ទ្រង់។



7

ព្រះទ្រង់ក៏បានបញ្ជាអោយស្មៅ, ផ្កា និងគុម្ពព្រៃ និងដើម ឈើលេចឡើង។ ហើយពួកវាក៏បានលេចឡើង បន្ទាប់មកក៏មានពេលល្ងាច និងពេលព្រឹកឡើង ជាថ្ងៃទីបី។



8

បន្ទាប់មក ទ្រង់បានបង្កើតព្រះអាទិត្យ និងព្រះចន្ទ និងផ្កាយជាច្រើនដែលគ្មាននរណាម្នាក់អាចរាប់អស់ឡើយ។ ហើយក៏មានពេលល្ងាច និងពេលព្រឹកឡើងជាថ្ងៃទីបួន។



9

សត្វនៅក្នុងសមុទ្រ ហើយនឹងត្រី ព្រមទាំងបក្សាបក្សីស្ថិតនៅក្នុងបញ្ជីបន្ទាប់របស់ព្រះ។ នៅថ្ងៃទីប្រាំ ទ្រង់បានបង្កើតត្រីមាត់ធារធំៗ និងត្រីតូចៗជាច្រើន, ព្រមទាំងសត្វអូទ្រីសដែលមានជើងវែងៗ និងសត្វស្លាបតូចៗដែលស្រែកច្រៀងយ៉ាងពិរោះ។ ព្រះបានបង្កើតគ្រប់ប្រភេទត្រីដើម្បីបំពេញក្នុងទឹក ហើយនឹងគ្រប់ប្រភេទបក្សាបក្សីអោយកំសាន្តសប្បាយនៅលើដី, ក្នុងសមុទ្រ និងនៅលើអាកាស។ ហើយក៏មានពេលល្ងាច និងពេលព្រឹកឡើងជាថ្ងៃទីប្រាំ។



10

បន្ទាប់ពីនោះមក ព្រះបានមានបន្ទូលម្តងទៀតថា “សូមអោយផែនដីបង្កើតអោយមានជីវិតរស់នៅទីបួន...” សត្វគ្រប់ប្រភេទ, សត្វល្អិត និងពពួកសត្វលូនបានមានជីវិតឡើង។ ហើយក៏មានសត្វដំរីដ៏ធំសម្បើមដែលអាចដើរអោយរញ្ជួយដី សត្វភេដែលតែងតែរស់ ព្រមទាំងសត្វស្វាក្រមិចក្រមើម និងសត្វក្រពើល្ងីល្ងើ ហើយក៏មានដង្កូវរួចខ្លួន និងសត្វកំប្រុកថ្ពាល់ប៉ោង, សត្វកវែង និងសត្វឆ្មាដែលស្រមុកខុលៗ។ សត្វគ្រប់ប្រភេទត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់នៅថ្ងៃនោះ។ ហើយក៏មានពេលល្ងាច និងពេលព្រឹកឡើងជាថ្ងៃទីប្រាំមួយ។



11

ព្រះទ្រង់បានបង្កើតអ្វីមួយទៀតនៅថ្ងៃទីប្រាំមួយនឹង អ្វីម៉្យាងដែលពិសេសខ្លាំង។ ពេលនេះគ្រប់យ៉ាងត្រៀមជាស្រេចសំរាប់មនុស្ស។ មានចំនីអាហារនៅទីវាល និងមានសត្វនៅចាំបម្រើគេ។ ហើយព្រះជាម្ចាស់បានមានបន្ទូលថា “ចូរអោយមនុស្សមានរូបរាងដូចជារូបយើង។ សូមអោយគេជាម្ចាស់លើគ្រប់យ៉ាងដែលមានលើផែនដីនេះ។” ដូច្នេះព្រះជាម្ចាស់បានបង្កើតមនុស្សក្នុងរូបភាពផ្ទាល់របស់ទ្រង់, នៅក្នុងរូបភាពរបស់ទ្រង់ ទ្រង់បានបង្កើតគាត់...



12

ព្រះបានមានព្រះបន្ទូលទៅអាដាមថា “បរិភោគនូវអ្វីដែលអែងចង់ពីក្នុងសួនបាន លើកលែងតែដើមដឹងខុសត្រូវ។ ប្រសិនបើអែងបរិភោគពីដើមនោះ អែងប្រាកដជាស្លាប់ជាមិនខាន។”



13

ហើយព្រះបានមានបន្ទូលថា “វាមិនល្អឡើយដែលមនុស្សនៅឯការម្នាក់ឯង។ យើងនឹងបង្កើតជំនួយម្នាក់ដល់គេ។” ទ្រង់បាននាំយកនូវសត្វបក្សាបក្សី និងសត្វសាហាវគ្រប់ប្រភេទទៅអោយអាដាម។ អាដាមបានដាក់ឈ្មោះអោយពួកសត្វទាំងនោះ។ អាដាមប្រាកដជាឆ្លាតណាស់ហើយដែលអាចធ្វើរឿងនឹងបាន។ ប៉ុន្តែក្នុងចំណោមសត្វទាំងអស់នោះ មិនមានសត្វមួយណាដែលសាកសមជាដៃគូរជាមួយអាដាមឡើយ។



14

ព្រះជាម្ចាស់បានធ្វើអោយអាដាមដេកលង់លក់ស្កប់ស្កល់ ហើយទ្រង់បានដកយកឆ្អឹងជំនីមួយពីអាដាម ទ្រង់បានបង្កើតស្រ្តីម្នាក់ពីឆ្អឹងជំនីអាដាម។ ស្រ្តីដែលព្រះជាម្ចាស់បានបង្កើតល្អសាកសមជាដៃគូរបស់អាដាមពិតមែន។



15

ព្រះទ្រង់បានបង្កើតគ្រប់យ៉ាងក្នុងពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ព្រះជាម្ចាស់បានអោយពរដល់ថ្ងៃទីប្រាំពីរ ហើយបានយកវាធ្វើជាថ្ងៃសំរាក។ នៅក្នុងសួនអ៊ីដែន អាដាម និងភរិយារបស់គាត់, អ៊ីវ មានសុភមង្គលល្អឥតទាស់គ្រាប់បង្គាប់របស់ព្រះ។ ព្រះ ជាម្ចាស់របស់ពួកគេ, ជាអ្នកផ្តល់ទំនុកបម្រុងដល់ពួកគេ និងជាមិត្តរបស់ពួកគេ។



16

ពេលព្រះជាម្ចាស់បានបង្កើតរបស់គ្រប់យ៉ាង

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគុម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ១-២

"ការបើកសម្តែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។"
ទំនុកតម្កើង ១១៩៖ ១៣០

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់ ដែលទ្រង់ហៅការទាំងនោះថាអំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់។

ព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ពេលនេះព្រះអង្គអាចអភ័យទោសរាល់អំពើបាបរបស់យើងបានហើយ។

ប្រសិនបើអ្នកចង់បែរចេញពីអំពើបាបរបស់អ្នក អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ព្រះអង្គអើយ ទូលបង្គំជឿហើយថា ព្រះយេស៊ូបានសុគតជំនួសខ្ញុំ ហើយទ្រង់បានរស់ឡើងវិញពីសេចក្តីស្លាប់។ សូមទ្រង់ចូលមកក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីអោយទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយបន្ទាប់មកនឹងបានទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយរស់នៅសំរាប់ទ្រង់ ដូចជាបុត្ររបស់ទ្រង់។
អាមែន។ យ៉ូហាន ៣៖១៦

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទូលទៅកាន់ព្រះជារៀងរាល់ថ្ងៃ!